# ស័ង្ខ

ស័ង្ខ ជាប្រភេទខ្យងសមុទ្រម្យ៉ាង មានសណ្ឋាននិងរូបរាងល្អស្រស់ណាស់ ដែលគេយកមកច្នៃជាគ្រឿងលម្អសម្រាប់ដាក់តាំងនៅតាមគេហដ្ឋានឬការិយាល័យនានា។ គេក៏យកខ្យងស័ង្ខទៅប្រើប្រាស់សម្រាប់ដាក់វត្ថុផ្សេងៗ ដូចជាដាក់ទឹក និងធ្វើទៅជាឧបករណ៍តន្ត្រីហៅថា «ខ្យងស័ង្ខ» ឬ «ស័ង្ខ» ដោយកាត់គូទចោលបន្តិចឱ្យមានរន្ធជាបំពង់សម្រាប់ផ្លុំ។

ខ្យងស័ង្ខ ឬស័ង្ខ ជាឧបករណ៍តន្ត្រីមួយប្រភេទដែលមានអាយុកាលចាស់។ សៀវភៅ «តន្ត្រីខ្មែរ» Musique Khmère បានកំណត់ឫសគល់និងប្រភពរបស់ឧបករណ៍ស័ង្ខទៅវប្បធម៌តន្ត្រីមនខ្មែរ។[១] ឧបករណ៍តន្ត្រីស័ង្ខ មានសូរ «ទូត» តែមួយប៉ុណ្ណោះ ដូច្នេះមិនអាចបញ្ចេញជាបទភ្លេងអ្វីមួយបានឡើយ។ យ៉ាងណាមិញ ស័ង្ខ មានសូរធ្ងន់និងជ្រៅជាសណ្ឋានទឹករលកដោយការប្រើបបូរមាត់និងដង្ហើមរបស់អ្នកផ្លុំ។

គេឃើញមាន ខ្យងស័ង្ខ ឬ ស័ង្ខ នៅក្នុងតំបន់ជាច្រើនលើពិភពលោក។ នៅប្រទេសឥណ្ឌា គេហៅខ្យងស័ង្ខឬស័ង្ខនេះថា «sankhu» ដែលគេប្រើប្រាស់នៅក្នុងពិធីសាសនានៅតាមវត្តអារាមដែលគេតែងតែឮសូរសំឡេង ដូចជាការហែក្បួនឬនៅក្នុងនិងក្រៅព្រះវិហារនៅមុខព្រះបដិមាសក្ការៈហិនឌូ។[២]

គេយកខ្យងស័ង្ខដែលមានសណ្ឋាននិងរូបរាងប្លែកគ្នាជាច្រើនប្រភេទ និងទំហំតូចធំទៅច្នៃ។ ខ្យងខ្លះ គេយកទៅឆ្លាក់ជារូបផ្សេងៗ ទៅជាវត្ថុសិល្បៈនិងវត្ថុសក្ការៈសម្រាប់តាំងនិងថ្វាយបូជានៅក្នុងពិធីសាសនា ដូចដែលយើងឃើញមាននៅប្រទេសឥណ្ឌា ជាដើម។

នៅកម្ពុជា គេប្រើស័ង្ខពិសេសតែនៅក្នុងព្រះរាជពិធិផ្សេងៗក្នុងនិងក្រៅព្រះបរមរាជវាំង។ បារគូដែលជាព្រាហ្មណ៍បុរោហិត (អ្នកថែរក្សាព្រះខ័ន្ធរាជនិងទេវរូប ព្រមទាំងព្រះរាជពិធីក្នុងព្រះបរមរាជវាំង) ប្រើឧបករណ៍តន្ត្រីខ្មែរបុរាណមួយនេះ ដើម្បីនឹងដួសទឹកនៅក្នុងព្រះរាជពិធី ឬផ្លុំផ្ដល់ជាសូរ «ទូត ទូត» ជាសញ្ញា និងដើម្បីថ្វាយព្រះពរជ័យ ដងនិងស្រោចទឹកមន្តសក្តិសិទ្ធជ័យមង្គល ថ្វាយទឹកក្លស្សស័ង្ខនិងថ្វាយស្លឹកព្រះញ្ញៅ ថ្វាយដល់ព្រះមហាក្សត្រ ជាពិសេសព្រះរាជពិធីសិរីមង្គល ចម្រើនព្រះជន្ម និងព្រះរាជាភិសេក។

---

[១] 1969: 5

[២] Vaidyanathan 1994: 167, 172

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

នៅក្រៅព្រះបរមរាជវាំង  យើងក៏ឃើញមានបារគូផ្លុំស័ង្ខនៅក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល និងព្រះរាជពិធីបួងសួងសុំព្រះអគ្គីដើម្បីថ្វាយព្រះភ្លើង។[៣]





[៣] Smithies 1986: 72

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

## ឯកសារពិគ្រោះ

*កែវ ណារុំ*. (២០១១).
*តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។
*Musique Khmère*.
(1969). Phnom Penh: Imprimerie Sangkum Réastr Niyum.
Sam, Sam-Ang.
(2002). *Musical Instruments of Cambodia*. Osaka, Japan: National Museum of Ethnology.
Smithies, Michael.
(1986). *Old Bangkok*. Singapore: Oxford University Press.
Vaidyanathan, Lalitha.
(1994). "The Musical Instruments of India," *Evolving Traditions*, ed. Joseph Peters. Singapore: The National Arts Council, 161-172.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION